# ឱវាទសម្រាប់មាតាបិតា

ទុកពេលសម្រាប់អានជារៀងរាល់ថ្ងៃ ហើយឲ្យទៀងទាត់។ ជ្រើសរើសពេលវេលាដែលល្អបំផុតសម្រាប់កូនរបស់លោកអ្នក។

ជួយកូនជ្រើសរើសសៀវភៅដែលត្រូវតាមកម្រិតរបស់ពួកគេ ហើយជាសៀវភៅដែលពួកគេចង់អាន។

រកអ្នកណាម្នាក់ឲ្យអានជាមួយកូនលោកអ្នក ហើយអានឮៗ! ក្មេងអាចអានបានកាន់តែល្អនៅពេលដែលពួកគេស្ដាប់ឮអ្នកដទៃទៀតអានឮៗ។

យកសៀវភៅទៅតាម នៅពេលធ្វើដំណើរកំសាន្ត ឬ ទៅកន្លែងមើលថែក្មេង។ ក្មេងចូលចិត្តបង្ហាញនូវអ្វីៗដែលពួកគេអានជាមួយអ្នកដទៃទៀត ហើយការធ្វើដូច្នេះធ្វើឲ្យមានឱកាសបង្កើនការ និយាយ និងស្ដាប់ និងកាន់តែមានឱកាសអានថែមទៀត។

ការអាន និង ការសរសេរ សំខាន់ដូចគ្នា ដូច្នេះត្រូវជំរុញកូនលោកអ្នកឲ្យសរសេរអំពីសៀវភៅដែលពួកគេបានអាន។ កំណត់ហេតុប្រចាំថ្ងៃនៃការអាន គឺជាវិធីដ៏ល្អដើម្បីឲ្យដឹងនូវអ្វីៗដែលបានអាន និង ដើម្បីរៀនសរសេរ។